**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តឧត្តរមានជ័យ**
**គណៈកម្មាធិការលទ្ធកម្ម**
លេខៈ៣៦៨/១៨សជណ/ឧជ

ថ្ងៃសុក្រ ១រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ឧត្តរមានជ័យ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១៨

## សេចក្តីជូនដំណឹង
## ស្តីពីការអញ្ជើញចូលរួមដេញថ្លៃការងារជួសជុល និងសាងសង់

រដ្ឋបាលខេត្តឧត្តរមានជ័យ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុនទទួលការងារជួសជុល/សាងសង់ក្នុងស្រុក (គិតទាំងសហគ្រាសឯកត្តបុគ្គល) និងក្រុមហ៊ុនបរទេសទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា រដ្ឋបាលខេត្តឧត្តរមានជ័យនឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការជួសជុល/សាងសង់មានដូចខាងក្រោម៖

១-ការងារជួសជុល និងតំឡើងបង្គោលភ្លើងបំភ្លឺសាធារណៈចំនួន៨០ដើម កំពស់១០ម៉ែត្រ ចាប់ពីរង្វង់មូលជ័យវរ្ម័នទី៧ដល់រង្វង់មូលព្រះកេស្វារ និងចំនួន១០ដើម កំពស់៧ម៉ែត្រ ផ្លូវកណ្តាលសួន ចាប់ពីវិមានឯករាជ្យដល់រូបនាគខាងកើតជូនរដ្ឋបាលខេត្តឧត្តរមានជ័យ (ការងារដេញថ្លៃ)

រដ្ឋបាលខេត្តឧត្តរមានជ័យបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុនបំពេញដើម្បីចូលរួមដេញថ្លៃ ហើយមានដាក់លក់នៅអង្គភាពលទ្ធកម្មដែលមានអាសយដ្ឋានក្នុងសាលាខេត្តឧត្តរមានជ័យចាប់ពីថ្ងៃទី ...១១...... ខែកញ្ញា..... ឆ្នាំ ២០១៨ តទៅរៀងរាល់ម៉ោងធ្វើការ។

ឯកសារដេញថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មយ៉ាងយូរបំផុតត្រឹមថ្ងៃទី.....១៨...... ខែ តុលា...... ឆ្នាំ ២០១៨ វេលាម៉ោង ១៦.ម៉.៣០.នាទីរសៀល

ការបើកឯកសារដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើវេលាម៉ោង១៦ម៉.៣០ នាទីរសៀល....នៅថ្ងៃទី....១៨..... ខែ តុលា......ឆ្នាំ ២០១៨។

ក្រុមហ៊ុនដែលមានបំណងចូលរួមដេញថ្លៃ សូមទាក់ទងជាមួយអង្គភាពលទ្ធកម្មសាលាខេត្តឧត្តរមានជ័យ ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ។
<u>បញ្ជាក់</u>៖ក្រុមហ៊ុនដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់ឯកសារដេញថ្លៃបានតែមួយគត់។

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

**អភិបាលខេត្ត និងជា**
**ប្រធានគណៈកម្មាធិការលទ្ធកម្មខេត្ត**

ស. ជាទី

សូមទំនាក់ទំនង ទូរស័ព្ទលេខ 097 992 113 5

**<u>ចម្លងជូន៖</u>**
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
-អង្គភាពប្រឆាំងអំពើពុករលួយ
"ដើម្បីជូនជ្រាប"
-ឯកសារ-កាលប្បវត្តិ

4